# ផ្នែកទី IV
# គំនូសសញ្ញាផ្សេងៗ លើផ្ទៃផ្លូវ
## ( Other Road Markings )

គំនូសសញ្ញានេះមានរាងខុសៗគ្នា មានពណ៌ស ឬពណ៌លឿង ទៅតាមប្រភេទគំនូសសញ្ញានិមួយៗ ។

គំនូសសញ្ញាប្រភេទនេះត្រូវបានគេប្រើ សំរាប់គូសតំរឹមគន្លងផ្លូវ សំរាប់ថ្មើរជើងឆ្លងកាត់ សំរាប់រថយន្តចត សំរាប់រថយន្តក្រុងឈប់ ជាដើម ។ល។

# ផ្នែកទី IV. : គំនូសសញ្ញាផ្សេងៗ លើទ្រូងផ្លូវ ( Other Road Markings )



## គំនូសសញ្ញាតំរឹមគន្លងផ្លូវ (ផ្លូវមានចរាចរពីរទិស )
DIAGONAL HATCHED MARKINGS (TWO-WAY ROAD)

**លេខកូដ :PW03-M4-01**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង ឆ្នូតបញ្ឆិតទ្រូងផ្លូវ ប្រើសំរាប់ តំរឹមគន្លងផ្លូវ ដែលមានចរាចរ ពីរទិសផ្ទុយគ្នា ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



## គំនូសសញ្ញាតំរឹមគន្លងផ្លូវ (ផ្លូវឯកទិស )
CHEVRON MARKINGS (ONE-WAY ROAD)

**លេខកូដ :PW03-M4-02**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង រាងមុខព្រួញ លើទ្រូងផ្លូវ ប្រើសំរាប់ តំរឹមគន្លងផ្លូវ ដែលមានចរាចរ តែមួយទិស ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



## គំនូសសញ្ញាតំរឹមទ្រូងផ្លូវ (ជាប់គែមចិញ្ចើមផ្លូវ )
DIAGONAL HATCHED MARKINGS (ON ROAD EDGE)

**លេខកូដ :PW03-M4-03**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌ស ឆ្នូតបញ្ឆិតគែមចិញ្ចើមផ្លូវ ប្រើ សំរាប់ តំរឹមទ្រូងផ្លូវចរាចរ ដូចជានៅចុងសងខាង កន្លែងចត រថយន្ត ឬ កន្លែងចាំបាច់ផ្សេងទៀត ។ ហាមបើកបរជាន់ ឆ្លងកាត់ ឈប់ ឬ ចតលើគំនូសសញ្ញានេះ ។

---



## គំនូសសញ្ញា សំរាប់ថ្មើរជើងឆ្លងកាត់
CROSSWALK MARKINGS

**លេខកូដ :PW03-M4-04**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌ស កាត់ទទឹងទ្រូងផ្លូវ ជាកង់ៗ ប្រើ សំរាប់ ថ្មើរជើងឆ្លងកាត់ ។ ហាមយានជំនិះគ្រប់ប្រភេទ ឈប់ ឬ ចត ពីលើគំនូសសញ្ញានេះ ។



## គំនូសសញ្ញា លើទួល

ROAD HUMP MARKINGS

**លេខកូដ :PW03-M4-05**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿងឆ្នូតខ្មៅ បញ្ឈិតកាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់អោយអ្នកបើកបរប្រុងប្រយត្ន័ មានទួលនៅត្រង់ គំនូសនេះ ។

---



## គំនូសសញ្ញា សំរាប់រថយន្តក្រុងឈប់

BUS STOP MARKINGS

**លេខកូដ :PW03-M4-06**

**ខ្លឹមសារ :** គំនូសសញ្ញាពណ៌លឿង រាងធ្មេញរណា ប្រើដើម្បីកំណត់ទីកន្លែង សំរាប់តែរថយន្តក្រុង ឈប់ ។

---



## គំនូសសញ្ញា សំរាប់រថយន្តចត (ស្របគែមចិញ្ចើមផ្លូវ)

PARKING BAY MARKINGS (PARALLEL PARKINGS)

**លេខកូដ :PW03-M4-07**

**ខ្លឹមសារ :** គំនូសសញ្ញាដាច់ៗពណ៌ស រាងចតុកោណកែង ដែលមានជ្រុងវែង ស្របទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។

---



## គំនូសសញ្ញា សំរាប់រថយន្តចត (កែងគែមចិញ្ចើមផ្លូវ)

PARKING BAY MARKINGS (VERTICAL PARKINGS)

**លេខកូដ :PW03-M4-08**

**ខ្លឹមសារ :** គំនូសសញ្ញា ពណ៌ស រាងចតុកោណកែង ដែលមានជ្រុងវែងជាគំនូសជាប់ ហើយកែងទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។



**គំនូសសញ្ញា សំរាប់រថយន្តចត (បញ្ឆិតគែមចិញ្ចើមផ្លូវ)**

PARKING BAY MARKINGS (ANGLED PARKINGS)

**លេខកូដ :PW03-M4-09**

**ខ្លឹមសារ :** គំនូសសញ្ញា ពណ៌ស រាងចតុកោណ ដែលមាន ជ្រុងវែងជាគំនូសជាប់ ហើយបញ្ឆិតទៅនឹងគែមចិញ្ចើមផ្លូវ ប្រើដើម្បីកំណត់ទីកន្លែង អោយរថយន្តចត ក្នុងចន្លោះសញ្ញានេះ ។